អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងនឹងផ្អាកធ្វើសវនាការក្នុងសំណុំរឿង ០០២ មួយរយៈពេលខ្លី

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងផ្អាកធ្វើសវនាការលើសំណុំរឿង ០០២ មួយរយៈពេលខ្លី ដើម្បីរៀបចំកិច្ចការនានាសម្រាប់សវនាការនាពេលខាងមុខ បន្ទាប់ពីបញ្ចប់សវនាការវគ្គទីមួយក្នុងឆ្នាំ២០១២។ សវនាការលើសំណុំរឿង ០០២ ប្រឆាំងនឹងជនជាប់ចោទ ខៀវ សំផន នួន ជា និង អៀង សារី នឹងបន្តធ្វើនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២។

តាំងពីការចាប់ផ្តើមនៃការធ្វើសេចក្តីសន្និដ្ឋានបទចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ សាធារណជនចំនួន ២០ ២៥៧ នាក់បានចូលរួមតាមដានសវនាការដោយផ្ទាល់នៅសាលសវនាការនៃ អ.វ.ត.ក។ សមាសភាពនេះរួមមាន សិស្ស និស្សិត តំណាងអង្គការក្រៅរដ្ឋាភិបាល ភ្ញៀវអន្តរជាតិ និងប្រជាជនកម្ពុជាមកពីគ្រប់ទិសទីនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈកម្មវិធីផ្សព្វផ្សាយរបស់តុលាការ។ ជាងនេះទៅទៀត មានអ្នកតាមដានការផ្សាយបន្តផ្ទាល់តាមប្រព័ន្ធ វីដេអូអ៊ិនធឺណិត របស់ អ.វ.ត.ក ជាមធ្យម ៧១ នាក់ក្នុងមួយថ្ងៃៗ។ ការផ្សាយបន្តផ្ទាល់តាមប្រព័ន្ធ វីដេអូអ៊ិនធឺណិត ដែលផ្តល់ជូនដោយ អ.វ.ត.ក នេះកំពុងស្ថិតនៅក្នុងដំណាក់កាលសាកល្បងនៅឡើយ និងមានតែភាសាអង់គ្លេសប៉ុណ្ណោះ។

តាំងពីការចាប់ផ្តើមនៃការធ្វើសេចក្តីសន្និដ្ឋានបទចោទប្រកាន់ សវនាការនៃអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២ បានប្រព្រឹត្តទៅរយៈពេលសរុបចំនួន ៣៣ថ្ងៃ។ នៅក្នុងអំឡុងពេលនេះ ក្រៅពីបានសួរដេញដោលជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងក៏បានសួរដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២រូប និងបានសួរសាក្សីចំនួន ៥រូប។ សំណុំឯកសារនៅក្នុងសំណុំរឿង ០០២ មានសរុបទាំងអស់ចំនួន ៥៦៤ ០០០ ទំព័រ៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥(0) ២៣ ៨១៤ លេខបន្ត: ៦១៦៩
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨ ៣២៨៣
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh